# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារនៃការដាក់ឯកសារ

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី៣ ខែតុលា ឆ្នាំ២០១១ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date):03-Oct-2011, 11:54
CMS/CFO:Kauv Keoratanak

## ចំណាត់ថ្នាក់ឯកសារ

ប្រភេទឯកសារស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយ កសចស ឬ អង្គជំនុំជម្រះ: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

# សំណើរបស់សហព្រះរាជអាជ្ញាសុំការអនុញ្ញាតដើម្បីឆ្លើយតប និងការឆ្លើយតបទៅនឹងចម្លើយតបរបស់ អៀង សារី ពាក់ព័ន្ធនឹងចេតនារបស់ជនជាប់ចោទ ទាក់ទងនឹងការផ្ដល់សក្ខីកម្ម

---

**អ្នកដាក់ឯកសារ:**

សហព្រះរាជអាជ្ញា:
លោកស្រី ជា លាង
លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**

អង្គជំនុំជម្រះសាលាដំបូង:
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រមJean-Marc LAVERGNE
ចៅក្រម យូរ ឧត្តរា

សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី:

**ចម្លងជូន:**

ជនជាប់ចោទ:
នួន ជា
អៀង សារី
អៀង ធីរិទ្ធ
ខៀវ សំផន

មេធាវីការពារក្ដីជនជាប់ចោទ:
លោក សុន អរុណ
លោក Michiel PESTMAN

| | |
|---|---|
| លោក ពេជ អង្គ | លោក Victor Koppe |
| Elisabeth SIMONNEAU FORT | លោក អាង ឧត្តម |
| | លោក Michael G.KARNAVAS |
| | លោក ផាត់ ពៅស៊ាង |
| | កញ្ញា Diana ELLIS |
| | លោក ស ស្វរ៉ាន |
| | លោក Jacques VERGÈS |

## I. សេចក្តីផ្តើម និងសំណើសុំការអនុញ្ញាតដើម្បីឆ្លើយតប

១- សហព្រះរាជអាជ្ញាស្នើសុំការអនុញ្ញាតដើម្បីឆ្លើយតបទៅនឹង "ចម្លើយតបរបស់ អៀង សារី ទៅនឹងសំណើបន្ថែមរបស់សហព្រះរាជអាជ្ញាសុំការណែនាំពាក់ព័ន្ធនឹងចេតនារបស់ជនជាប់ចោទ ទាក់ទងនឹងការផ្តល់សក្ខីកម្ម" ដែលបានដាក់ជូននៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១ ("ចម្លើយតប")[1]។ ដើម្បីសន្សំសំចៃថវិការបស់អង្គជំនុំជម្រះ ការឆ្លើយតបជាសារធាតុត្រូវបានធ្វើឡើងនៅខាងក្រោមនេះ។ សហព្រះរាជអាជ្ញាដាក់សេចក្តីសន្និដ្ឋានថា ការឆ្លើយតប គឺមានលក្ខណៈចាំបាច់ដោយហេតុថា៖ ទី១) បញ្ហាដែលនៅចំពោះមុខអង្គជំនុំជម្រះជាបញ្ហាស៊ីជម្រៅសំខាន់ចំពោះការត្រៀមរៀបចំឲ្យមានប្រសិទ្ធភាពសម្រាប់សវនាការ, ទី២) ការឆ្លើយតបនេះកែតម្រូវទៅលើការបកស្រាយដោយភាន់ច្រឡំរបស់ អៀង សារី ទាក់ទិនទៅនឹងសេចក្តីថ្លែងអំពីច្បាប់, និងទី៣) ការឆ្លើយតបនេះក៏ជាចម្លើយតបទៅនឹងការបកស្រាយដោយភាន់ច្រឡំរបស់ អៀង សារី ផងដែរទាក់ទិនទៅនឹងការដាក់ឯកសារចុំដែល។ វាគឺស្ថិតនៅក្នុងផលប្រយោជន៍នៃយុត្តិធម៌ ក្នុងការអនុញ្ញាតឲ្យមានការដាក់ការឆ្លើយតបដ៏សង្ខេបនេះ។

## II. ប្រវត្តិនីតិវិធី

២- កាលពីថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ សហព្រះរាជអាជ្ញាបានដាក់ "សំណើរបស់សហព្រះរាជអាជ្ញាស្នើសុំសេចក្តីណែនាំទាក់ទងនឹងចេតនារបស់ជនជាប់ចោទពាក់ព័ន្ធនឹងការផ្តល់សក្ខីកម្ម"[2] ("សំណើទី១")។ នៅក្នុងសំណើទីមួយនេះ សហព្រះរាជអាជ្ញាបានកាត់សម្គាល់ថាវាមានលក្ខណៈជានីតិវិធីប្រព័ន្ធច្បាប់ស៊ីវិលជាធរមាននៅចំពោះមុខ អវតក ដែលគេអញ្ជើញជនជាប់ចោទ ឲ្យផ្តល់សក្ខីកម្មនៅពេលចាប់ផ្តើមសវនាការ។ សហព្រះរាជអាជ្ញាបានបញ្ជាក់ពីសារៈសំខាន់របស់អង្គជំនុំជម្រះសាលាដំបូង និងភាគីនានាក្នុងការទទួលបាននូវការជូនដំណឹងពីចេតនារបស់ជនជាប់ចោទទាក់ទងនឹងការផ្តល់សក្ខីកម្ម នៅក្នុងសំណុំរឿងលេខ០០២ ឲ្យបានមុនពេលចាប់ផ្តើមសវនាការ។ សហព្រះរាជអាជ្ញាបានស្នើសុំថាត្រូវបង្គាប់ឲ្យជនជាប់ចោទបញ្ជាក់ពីចេតនារបស់ខ្លួន ក្នុងរយៈពេលចំនួនប្រាំពីរ(០៧)ថ្ងៃ[3]។

---

[1] **E101/2** ចម្លើយតបរបស់ អៀង សារី ទៅនឹង សំណើបន្ថែមរបស់សហព្រះរាជអាជ្ញា សុំការណែនាំពាក់ព័ន្ធចេតនារបស់ជនជាប់ចោទទាក់ទងនឹងការផ្តល់សក្ខីកម្ម, ថ្ងៃទី២២ កញ្ញា ២០១១ ("ចម្លើយតប") ។

[2] **E101** សំណើរបស់សហព្រះរាជអាជ្ញា ស្នើសុំសេចក្តីណែនាំទាក់ទងនឹងចេតនារបស់ជនជាប់ចោទពាក់ព័ន្ធនឹងការផ្តល់សក្ខីកម្ម, ថ្ងៃទី១៧ មិថុនា ២០១១ ។

[3] ដដែលដូចមុន, ត្រង់កថាខណ្ឌទី ២, ៣, ៥, ៦ ។

៣- កាលពីថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១១ សហព្រះរាជអាជ្ញាបានដាក់ "សំណើបន្ថែមរបស់សហព្រះរាជអាជ្ញាស្នើសុំសេចក្តីណែនាំពាក់ព័ន្ធនឹងចេតនារបស់ជនជាប់ចោទទាក់ទងនឹងការផ្តល់សក្ខីកម្ម" ("សំណើបន្ថែម") ដែលនៅក្នុងនោះ សហព្រះរាជអាជ្ញាបានបញ្ជាក់លើសំណើទីមួយរបស់ខ្លួនម្តងទៀត[4]។ នៅក្នុងចម្លើយតបរបស់ខ្លួន អៀង សារី បានផ្តល់សំអាងថា៖ ទី១) ទាំងវិធានផ្ទៃក្នុង ឬទាំងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាមិនមានចែងពីលំដាប់លំដោយក្នុងការតាំងសំណួរដល់ជនជាប់ចោទ ឬស្តាប់ចម្លើយសាក្សីទេ, ទី២) មិនមានអ្វីហាមឃាត់ដល់ជនជាប់ចោទមិនឱ្យផ្តល់សក្ខីកម្ម នៅដំណាក់កាលណាមួយក៏ដោយនៃសវនាការទេ និងមិនឱ្យបង្ហាញពីបំណងរបស់ពួកខ្លួននៅដំណាក់កាលក្រោយនោះទេ, និងទី៣) ដោយពិចារណាលើសំណើពីមុនៗរបស់សហព្រះរាជអាជ្ញា ដែលជំទាស់នឹងការដាក់ឯកសារច្រំដែលនានា សំណើបន្ថែមគឺជារឿងលាក់ពុត[5]។

៤- នៅក្នុងការឆ្លើយតបនេះ សហព្រះរាជអាជ្ញា៖ ទី១) ជូនសេចក្តីសន្និដ្ឋានថា នីតិវិធីជាធរមាននៅចំពោះមុខអង្គជំនុំជម្រះនេះ បានគ្រោងទុកជាមុនថា ជនជាប់ចោទត្រូវផ្តល់ភ័ស្តុតាងនៅពេលចាប់ផ្តើមសវនាការ, ទី២) បញ្ជាក់ពីសំណើរបស់ខ្លួនម្តងទៀតថា គេត្រូវបង្គាប់ឱ្យជនជាប់ចោទបញ្ជាក់ពីបំណងរបស់ខ្លួនក្នុងពេលឥឡូវនេះ ទាក់ទងទៅនឹងការផ្តល់សក្ខីកម្ម ដោយហេតុថា ការណ៍នេះនឹងជួយសម្រួលដល់ការត្រៀមរៀបចំសវនាការឱ្យបានតាមលំដាប់លំដោយ និងជួយដល់ការដឹកនាំធ្វើសវនាការឱ្យបានឆាប់រហ័ស, និងទី៣) ជូនសេចក្តីសន្និដ្ឋានថា សំណើបន្ថែមនោះ គឺមិនមែនជាការដាក់ឯកសារច្រំដែលនោះទេ។

## III. អំពីច្បាប់

៥- ការស្ទាបស្ទង់មតិសង្ខេបមួយ ស្តីពីយុត្តាធិការនានាដែលអនុវត្តច្បាប់ស៊ីវិល/នីតិវិធីព្រហ្មទណ្ឌស៊ើបអង្កេតដោយចៅក្រម បានបង្ហាញយ៉ាងច្បាស់លាស់ថា កិច្ចដំណើរការនីតិវិធីបង្ហាញភ័ស្តុតាងនៅចំពោះមុខតុលាការជំនុំជម្រះក្តីនៅក្នុងយុត្តាធិការទាំងនោះ ចាប់ផ្តើមឡើងដោយមានការតាំងសំណួរទៅលើ

[4] **E101/1** សំណើបន្ថែមរបស់សហព្រះរាជអាជ្ញា ស្នើសុំសេចក្តីណែនាំពាក់ព័ន្ធនឹងចេតនារបស់ជនជាប់ចោទ ទាក់ទងនឹងការផ្តល់សក្ខីកម្ម ។

[5] ចម្លើយតប, ត្រង់កថាខណ្ឌទី ២, ៣, ៤ និង ៥ ។

ជនជាប់ចោទ។ ជាឧទាហរណ៍ នៅក្នុងការប្រៀបធៀបគ្នារវាងបែបសួរតទល់គ្នា និងបែបស៊ើបអង្កេតដោយចៅក្រម ម្ចាស់អត្ថបទមួយរូបបានធ្វើអត្ថាធិប្បាយថា៖

*ការពិចារណាពីគោលជំហររបស់ចុងចម្លើយនៅក្នុងបន្ទប់សវនាការនៅអឺរ៉ុប។ ដោយហេតុថា វាមិនមានលក្ខខណ្ឌតម្រូវណាមួយនៅទីនេះដែលអយ្យការបង្កើតបាននូវករណីណាមួយដែលគួរឱ្យជឿបាននៅមុនពេលដែលមេធាវីការពារក្តីបានដាក់ជូននូវភស្តុតាងរបស់ខ្លួននោះ។ វាគ្មានឧបសគ្គណាមួយក្នុងការដែលចាប់ផ្តើមធ្វើពីដំណាក់កាលនៃការទទួលយកសក្ខីកម្ម ដោយការតាំងសំណួរទៅលើចុងចម្លើយនោះឡើយ ហើយការណ៍នេះតាមពិតទៅ គឺជាវិធាននៅក្នុងប្រព័ន្ធនានានៅតាមអឺរ៉ុប...។ នៅក្នុងប្រព័ន្ធទាំងអស់នៅតាមអឺរ៉ុប គេប្រើប្រាស់ចុងចម្លើយជាប្រភពសក្ខីកម្មមួយនៅមុនពេលដែលគេពិនិត្យទៅលើភស្តុតាងដទៃទៀតណាមួយក៏ដោយនៅពេលសវនាការ [6] ។*

៦- ស្របគ្នាជាមួយនឹងការណ៍នេះ គេបានធ្វើអត្ថាធិប្បាយថា "យុត្តាធិការច្បាប់ស៊ីវិលមើលឃើញថា ជនជាប់ចោទថាជាប្រភពភស្តុតាងទីមួយ និងសំខាន់បំផុត ដែលគេត្រូវធ្វើការពិនិត្យមុនភស្តុតាង ក្នុងទម្រង់ផ្សេងៗទៀត នៅពេលសវនាការ"[7]។

៧- វិធីសាស្ត្រនេះបានផ្តើមឡើងនៅលើការសន្មតមួយដែលថា ជនជាប់ចោទធ្លាប់បានឆ្លងកាត់នូវការស៊ើបសួរមួយដ៏ទូលំទូលាយ។ ហេតុដូច្នេះហើយ គាត់បានស្គាល់យ៉ាងច្បាស់លាស់ពីភស្តុតាង ដែលត្រូវបានដាក់ចូលក្នុងសំណុំរឿង និងដែលគាំទ្រដល់បទចោទនានាទៅលើរូបគាត់។ នៅក្នុងកាលៈទេសៈទាំងនេះ ជនជាប់ចោទមិនអាចអះអាងបានទេថាគេបានធ្វើបុរេវិនិច្ឆ័យទៅលើរូបគាត់ ដោយតម្រូវឱ្យគាត់ផ្តល់ភស្តុតាង នៅពេលចាប់ផ្តើមធ្វើកិច្ចដំណើរការនីតិវិធីលើភស្តុតាង៖

*ការលើកការចោទប្រកាន់ពីការចាញ់ប្រៀបរបស់ជនជាប់ចោទតាមនីតិវិធីបារាំង ដោយត្រូវបានគេតម្រូវឱ្យធ្វើសេចក្តីសម្រេចថាតើត្រូវផ្តល់សក្ខីកម្ម មុនអយ្យការដាក់បង្ហាញភស្តុតាងរបស់ខ្លួន ឬយ៉ាងណានោះ គឺត្រូវបានកាត់បន្ថយយ៉ាងច្រើន បើសិនជាមិនត្រូវបានដកចេញដោយការដាក់*

---

[6] លោក Damaska, "ឧបសគ្គភស្តុតាងចំពោះការជំនុំជម្រះ និង គំរូពីរយ៉ាងស្តីពីនីតិវិធីព្រហ្មទណ្ឌ៖ ការសិក្សាប្រៀបធៀប", *ទស្សនាវដ្តីច្បាប់នៃសាកលវិទ្យាល័យ Pennsylvania* (ឆ្នាំ១៩៧៣), ត្រង់ទំព័រទី ៥២៨-៥២៩ (រំលង កំណត់សម្គាល់ជើងទំព័រ ចោល) ។

[7] J.K.Walker, "ការពិភាក្សាប្រៀបធៀបអំពីបុព្វសិទ្ធិប្រឆាំងនឹងការធ្វើពិរុទ្ធកម្មលើខ្លួនឯង", *ទិនានុប្បវត្តិច្បាប់អន្តរជាតិ និងច្បាប់ប្រៀបធៀបនៃសាលាច្បាប់នៅទីក្រុងញូវយ៉ក* (ឆ្នាំ១៩៩៣), ត្រង់ ៤ ។

*បង្ហាញសំណុំរឿងទាំងមូលទៅដល់មេធាវីការពារក្តីនៅមុនពេលសវនាការ ដូចដែលវាមានទៅក្នុងនោះ នៅទូទាំងដំណាក់កាលស៊ើបសួរមុនសវនាការ*[8] ។

៨- ក្នុងឆ្នាំ២០០៧ ការស្ទាបស្ទង់មតិមួយនៅទូទាំងពិភពលោកស្តីពីប្រព័ន្ធច្បាប់នានា ដែលពិពណ៌នាអំពីនីតិវិធីព្រហ្មទណ្ឌនៅក្នុងប្រទេសបារាំងដែលបានបំផុសគំនិតដល់ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មានចែងដូចតទៅ៖

> *ជាទូទៅ ការជំនុំជម្រះក្តីចាប់ផ្តើមឡើងដោយការដាក់សាក្សីឱ្យនៅដាច់ពីគ្នា ដែលបន្ទាប់ពីនោះមកតុលាការសួរចម្លើយជនជាប់ចោទ ហើយទទួលយកចម្លើយនោះ បើសិនជាមាន។ បន្ទាប់មកភាគីនានា និងមេធាវីការពារក្តីមានសិទ្ធិក្នុងការសួរជនជាប់ចោទ។ គេមិនដាក់ជនជាប់ចោទឱ្យស្ថិតនៅក្រោមសម្បថទេ ហើយតាមផ្លូវច្បាប់ គេមិនអាចបង្ខំឱ្យគាត់ឆ្លើយទៅនឹងសំណួរណាមួយឡើយ ក៏ប៉ុន្តែគាត់មិនអាចរារាំងមិនឱ្យគេសួរសំណួរនានាបានឡើយ ឬមួយក៏មិនអាចរារាំងដល់តុលាការមិនឱ្យទាញនូវការពិចារណាទល់នឹងការដែលគាត់នៅស្ងៀមមិននិយាយបានទេ*[9] ។

៩- វិធាន ៨៩*ស្ទួន* នៃវិធានផ្ទៃក្នុងសម្រាប់ អវតក ដែលដាក់ចំណងជើងថា "សវនាការលើអង្គសេចក្តី" បានចែងថា៖

> ១. ប្រធានអង្គជំនុំជម្រះសាលាដំបូងប្រកាសបើកសវនាការលើអង្គសេចក្តី។ ប្រធានអង្គជំនុំជម្រះសាលាដំបូងបង្គាប់ឱ្យក្រឡាបញ្ជីអានបទចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទ និងអាចបង្គាប់ឱ្យក្រឡាបញ្ជីអាននូវការវិភាគអង្គហេតុនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។
>
> ២. ***<u>នៅមុនពេលសួរចម្លើយជនជាប់ចោទ</u>*** សហព្រះរាជអាជ្ញាអាចធ្វើសេចក្តីសន្និដ្ឋានដោយសង្ខេបអំពីការចោទប្រកាន់ចំពោះជនជាប់ចោទ។ ជនជាប់ចោទ ឬមេធាវីរបស់ជនជាប់ចោទអាចធ្វើការឆ្លើយតបដោយសង្ខេបបាន។ (សង្កត់ន័យបន្ថែមដោយ*<u>អក្សរទ្រេត និងគូសបន្ទាត់ពីក្រោម</u>*)

---

[8] K van Dijkhorst, "សិទ្ធិក្នុងការនៅស្ងៀមមិននិយាយ - តើល្បែងមានតម្លៃស្មើនឹងទៀនឬ?" (អាចរកបាននៅគេហទំព័រ http://www.isrcl.org/Papers/van%20Dijkhorst.pdf), ត្រង់ទំព័រទី ២៣ (វំលង កំណត់សម្គាល់ជើងទំព័រ ចោល) ។ វិធីសាស្ត្រដូចគ្នា ត្រូវបានគេទទួលយកធ្វើតាមនៅក្នុងប្រទេសអាល្លឺម៉ង់ និង ប្រទេសន័រវេះ សូមអានទំព័រទី ២៦ និង ៣១ ។

[9] C. M. Bradley (ed), *នីតិវិធីព្រហ្មទណ្ឌ, ការសិក្សាស្រាវជ្រាវទូទាំងពិភពលោក* (បោះពុម្ពលើកទី ២), បណ្ឌិតសភាសារព័ត៌មាននៅរដ្ឋ Carolina, (ឆ្នាំ២០០៧), ត្រង់ទំព័រទី ២២៨ (វំលង កំណត់សម្គាល់ជើងទំព័រ ចោល) ។

១០- ក្រោយមក លំដាប់លំដោយនៃសក្ខីកម្ម (ជនជាប់ចោទ បន្ទាប់មក សាក្សី) ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងលំដាប់តៗគ្នា ដែលពាក់ព័ន្ធតាមវិធានផ្ទៃក្នុង (វិធាន ៩០ និង ៩១) ហើយទៅតាមពាក្យពេជន៍នៃវិធាន៩១*ស្ទួន* (លំដាប់លំដោយនៃដំណើរការនីតិវិធីក្នុងដំណាក់កាលជំនុំជម្រះ) ដែលបានចែងថា៖

> ប្រធានអង្គជំនុំជម្រះសាលាដំបូងត្រូវកំណត់លំដាប់លំដោយ ដែលចៅក្រម សហព្រះរាជអាជ្ញា មេធាវី និងភាគីដទៃទៀត មានសិទ្ធិសួរសំណួរទៅកាន់*ជនជាប់ចោទ សាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី*។ (សង្កត់ន័យបន្ថែមដោយ*អក្សរទ្រេត និងគូសបន្ទាត់ពីក្រោម*)

១១- ស្រដៀងគ្នានេះដែរ វិធាននានាដែលជាប់ទាក់ទងនឹង "ការសួរចម្លើយជនជាប់ចោទ" មាននៅក្នុងមាត្រា ៣២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។ រីឯមាត្រា ៣២៦ ចែងអំពី "ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ជនរងគ្រោះ សាក្សី និងអ្នកជំនាញ តាមលំដាប់លំដោយដែលខ្លួន [ប្រធានសវនាការ] យល់ឃើញថាមានប្រយោជន៍"។ មាត្រាទាំងនេះមាននៅក្នុងផ្នែកដែលមានចំណងជើងថា"ដំណើរការនៃកិច្ចពិភាក្សាដេញដោល" ដែលចែងអំពីបទប្បញ្ញត្តិនានាទៅតាមលំដាប់លំដោយមួយដែលឆ្លុះបញ្ចាំងពីដំណើរការនីតិវិធីច្បាប់ស៊ីវិល។ វាគ្រាន់តែជាការមួយដ៏សមហេតុផលក្នុងការទាញសេចក្តីសន្និដ្ឋានថា ការដាក់តាមលំដាប់លំដោយនៃបទប្បញ្ញត្តិនានាតាមរបៀបនេះ ក្រុមអ្នកធ្វើពង្រាងមានចេតនាដើរតាមលំដាប់លំដោយតៗគ្នានៃច្បាប់ស៊ីវិល ដែលបានរៀបរាប់នៅខាងលើ។

## IV. អំណះអំណាង

១២- ការអះអាងរបស់ អៀង សារី ដែលថា វិធានផ្ទៃក្នុង និងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មិនមានចែងអំពីលំដាប់លំដោយដែលគេត្រូវសួរជនជាប់ចោទ និងសាក្សីនោះ គឺខុសយ៉ាងច្បាស់ក្រឡែត។ ដូចដែលបានបញ្ជាក់នៅខាងលើហើយថា ទាំងវិធានផ្ទៃក្នុង និងទាំងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា បានឆ្លុះបញ្ចាំងពីលំដាប់លំដោយនៃដំណើរការនីតិវិធី ដែលបានរកឃើញនៅក្នុងប្រទេសនានាដែលប្រើច្បាប់ស៊ីវិល ខណៈដែលជនជាប់ចោទផ្តល់សក្ខីកម្មនៅពេលចាប់ផ្តើមសវនាការ។ វិធាន៨៩*(ស្ទួន)*២ បញ្ជាក់ថាជនជាប់ចោទនឹងផ្តល់សក្ខីកម្ម បន្ទាប់ពីសេចក្តីសន្និដ្ឋានបើកការចោទប្រកាន់ណាមួយ។

១៣- លើសពីនេះទៀត អំណះអំណាងរបស់ អៀង សារី ពាក់ព័ន្ធនឹងការដាក់វិធាន ៨៤ ("ការចូលខ្លួនរបស់សាក្សី និងអ្នកជំនាញ") នៅមុនវិធានទាំងឡាយខាងលើនេះ គឺជាការដាក់ដោយខុសឆ្គង។ វាមិនដូចជាវិធាន ៨៩*(ស្ទួន)* ដល់ ៩១*(ស្ទួន)* នោះទេ វិធាន៨៤ មិនមាននិយាយអំពីរបៀបដែលគេត្រូវដឹកនាំធ្វើសវនាការទេ ប៉ុន្តែផ្ទុយទៅវិញ និយាយអំពីសិទ្ធិរបស់ជនជាប់ចោទក្នុងការកោះហៅសាក្សីមួយចំនួនប៉ុណ្ណោះ។

១៤- សហព្រះរាជអាជ្ញាមិនមានបញ្ហាអ្វីជាមួយនឹងការអះអាងរបស់ អៀង សារី ដែលថាជនជាប់ចោទអាចធ្វើសេចក្តីថ្លែងនៅចំពេលណាមួយនៃសវនាការក៏បាននោះទេ - បើទោះជាជាក់ស្តែង ការណ៍នេះគឺត្រូវស្ថិតនៅក្រោមសិទ្ធិអំណាចរបស់ប្រធានអង្គជំនុំជម្រះ ទាក់ទងទៅនឹងការគ្រប់គ្រងសវនាការក៏ដោយ[10]។ សហព្រះរាជអាជ្ញារំលឹកឡើងវិញថានៅក្នុងសំណុំរឿងលេខ០០១ ខណៈដែលបានផ្តល់សក្ខីកម្មនៅពេលចាប់ផ្តើមសវនាការរួចហើយ ជនជាប់ចោទបានធ្វើសេចក្តីថ្លែងនានាបន្ថែមទៀត ក្នុងអំឡុងពេលនៃដំណើរការនីតិវិធីផ្តល់សក្ខីកម្ម។

១៥- វាមិនមែនជាគោលជំហររបស់សហព្រះរាជអាជ្ញាទេដែលថា បើជនជាប់ចោទសម្រេចចិត្តអនុវត្តសិទ្ធិរបស់ខ្លួន ក្នុងការនៅស្ងៀមមិននិយាយនៅពេលចាប់ផ្តើមសវនាការ គេ*ចាំបាច់* ត្រូវការពារគាត់មិនឲ្យផ្តល់សក្ខីកម្មនៅដំណាក់កាលក្រោយៗនៃសវនាការ។ យ៉ាងណាក៏ដោយ នីតិវិធីព្រហ្មទណ្ឌដែលកំពុងនៅជាធរមាននៅចំពោះមុខអង្គជំនុំជម្រះនេះ បានគ្រោងទុកជាមុនយ៉ាងច្បាស់ថា គេនឹងធ្វើការកោះហៅជនជាប់ចោទ ដើម្បីឲ្យមកផ្តល់សក្ខីកម្មនៅពេលចាប់ផ្តើមសវនាការ ហើយដោយសារតែទំហំ និងភាពស្មុគស្មាញនៃករណីរឿងនេះ នោះគឺវាចាំបាច់ និងសមស្របចំពោះ ជនជាប់ចោទក្នុងការថ្លែងអំពីគោលជំហររបស់ខ្លួនលើបញ្ហានេះ ឲ្យបានមុនពេលចាប់ផ្តើមធ្វើ នីតិវិធីផ្តល់សក្ខីកម្ម។ ការណ៍នេះនឹងជួយដល់អង្គជំនុំជម្រះ និងភាគីនានា ឲ្យមានលទ្ធភាពក្នុងការត្រៀមរៀបចំឲ្យមានប្រសិទ្ធភាព និងជួយសម្រួលដល់ការដឹកនាំធ្វើសវនាការឲ្យបានឆាប់រហ័ស។

---

[10] ដោយរួមទាំងសិទ្ធិអំណាចនានាដែលមានចែងនៅក្នុងវិធាន ៨៥ និង ៩១*(ស្ទួន)* នៃវិធានផ្ទៃក្នុង ផង ។

១៦- គេបានតម្រូវឱ្យអង្គជំនុំជម្រះសាលាដំបូងធានាថា សវនាការនានាត្រូវប្រព្រឹត្តទៅឱ្យបានទាំង ត្រឹមត្រូវ *និង*ទាំងឆាប់រហ័ស[11]។ សំណើមិនច្បាស់លាស់របស់ អៀង សារី ដែលថាជនជាប់ចោទទាំងអស់ អាចគ្រាន់តែជូនដំណឹងទៅអង្គជំនុំជម្រះនៅថ្ងៃដំបូងនៃដំណើរការនីតិវិធីផ្តល់សក្ខីកម្ម ថាតើពួកគាត់នឹងផ្តល់សក្ខីកម្មនៅចំពេលនោះ ឬមួយយ៉ាងណានោះ គឺមិនអាចការពារបានទេ ហើយយ៉ាងច្បាស់ណាស់ គឺមិនត្រូវគ្នាទៅនឹងទស្សនៈនៃសវនាការមួយដែលត្រូវធ្វើតាមលំដាប់លំដោយ និងឆាប់រហ័សនោះ។ ជនជាប់ចោទមានសិទ្ធិដើម្បីអនុវត្តបានដោយសេរី នូវសិទ្ធិក្នុងការទទួលបាននូវការកាត់សេចក្តីដ៏ត្រឹមត្រូវ ក៏ប៉ុន្តែការណ៍នេះមិនត្រូវធ្វើឱ្យតុលាការ និងភាគីផ្សេងៗទៀត ក្លាយជាចំណាប់ខ្មាំងដោយសារការគិតភ្លាមៗរបស់ពួកគាត់នោះទេ ឬមួយក៏មិនត្រូវធ្វើឱ្យជនជាប់ចោទមានសិទ្ធិដើម្បីពន្យារពេល និងធ្វើឱ្យដំណើរការនីតិវិធីមិនបានសម្រេច ដោយកាន់កាប់ទុកនូវព័ត៌មានសំខាន់ៗនោះក៏ទេដែរ។ ការសម្រេចចិត្តរបស់ជនជាប់ចោទ ពាក់ព័ន្ធនឹងការផ្តល់សក្ខីកម្មនៅពេលចាប់ផ្តើមសវនាការនឹងមានផលប៉ះពាល់យ៉ាងសំខាន់ទៅលើការត្រៀមរៀបចំដំណើរការនីតិវិធីផ្តល់សក្ខីកម្ម ដែលត្រៀមធ្វើឡើងដោយអង្គជំនុំជម្រះ និងភាគីទាំងអស់។

## V. បញ្ហាស្តីពីការដាក់ឯកសារច្រំដែល

១៧- អៀង សារី បានផ្តល់អំណះអំណាងថា សំណើបន្ថែមគឺជារឿងលាក់ពុត[12]។ គាត់អះអាងថា សំណើទីពីរស្តីពីបញ្ហាមួយដែលនៅចំពោះមុខអង្គជំនុំជម្រះរួចជាស្រេច គឺមិនអាចសម្រុះសម្រួលបានជាមួយនឹងគោលជំហររបស់សហព្រះរាជអាជ្ញា ដែលថាការលើកឡើងនូវបញ្ហាដូចៗគ្នាតាមផ្លូវច្បាប់ នៅក្នុងការដាក់ឯកសារជាបន្តបន្ទាប់នោះ គឺជាការច្រំដែល និងជាការមិនគោរពដល់ដំណើរការនៃការធ្វើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង[13]។ អំណះអំណាងនេះ គឺនាំឱ្យមានការយល់ខុស។ នៅក្នុងការដាក់ឯកសារដែល អៀង សារី បានយោងនោះ សហព្រះរាជអាជ្ញាបានជូនសេចក្តីសន្និដ្ឋានថា ការលើកឡើងនូវបញ្ហាដូចៗគ្នាតាមផ្លូវច្បាប់ នៅក្នុងការដាក់ញត្តិជាបន្តបន្ទាប់នោះ បានដាក់ទម្ងន់

---

[11] មាត្រា ៣៣ថ្មី នៃច្បាប់ អវតក ។

[12] ចម្លើយតប, ត្រង់កថាខណ្ឌទី ៥ ។

[13] ដដែលដូចមុន, ត្រង់កថាខណ្ឌទី ៤ ។

ដែលមិនចាំបាច់ទៅលើអង្គជំនុំជម្រះ និងភាគីទាំងអស់[14]។ អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានចាត់ការដោះស្រាយ លើការដែល អៀង សារី បានដាក់ឯកសារនានាដែលមិនចាំបាច់ និងច្រំដែល[15]។

១៨- សហព្រះរាជអាជ្ញាដាក់សេចក្តីសន្និដ្ឋានថា មានភាពខុសគ្នាដ៏សំខាន់មួយរវាង ម្យ៉ាង សំណើមួយ ដែលថាមានបញ្ហាមួយនៅចំពោះមុខអង្គជំនុំជម្រះដែលនៅមិនទាន់បានដោះស្រាយនៅឡើយ ត្រូវធ្វើឱ្យបានឆាប់រហ័ស ឬត្រូវធ្វើសេចក្តីសម្រេចលើសំណើនោះ ហើយម្យ៉ាងទៀត ការដាក់ជូនវិលចុះវិលឡើងនូវឯកសារនានាដែលមានអំណះអំណាងច្បាប់សំខាន់ៗដែលបានដាក់ជូនពីមុនៗ។ សំណើបន្ថែមនេះគឺច្បាស់ណាស់ វាស្ថិតនៅក្នុងប្រភេទពីមុន៖ គឺជាការដាក់ឯកសារមួយដែលមានអត្ថបទមិនដល់ពីរទំព័រផងដែលមានបំណងជួយសម្រួលដល់ការត្រៀមរៀបចំសវនាការនានា ដោយការស្វែងរកនូវសេចក្តីសម្រេចមួយលើសំណើដែលនៅមិនទាន់បានដោះស្រាយនៅឡើយ អស់រយៈពេលប្រមាណជាបីខែមកហើយ។ ការអះអាងរបស់ អៀង សារី ដែលថាសហព្រះរាជអាជ្ញាមានចេតនាឱ្យគេប្រព្រឹត្តមកលើខ្លួនឱ្យបានច្រើនជាងមេធាវីការពារក្តីនោះ គឺគ្រាន់តែជាការវៀចវេរមួយតែប៉ុណ្ណោះ។

## VI. សំណើ

១៩- សហព្រះរាជអាជ្ញាកត់សម្គាល់ថា ចាប់តាំងពីមានការដាក់ឯកសារបន្ថែមនេះមក អង្គជំនុំជម្រះបានចាត់ការជាជំហានបន្តទៀត ក្នុងការជួយសម្រួលដល់ការត្រៀមរៀបចំដំណើរការនីតិវិធីផ្តល់ភស្តុតាង

[14] **E114/1**, ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹង "ការជំទាស់របស់ អៀង សារី ទៅនឹងភាពអាចទទួលយកបាននូវប្រភេទឯកសារមួយចំនួន", ថ្ងៃទី១៦ កញ្ញា ២០១១, ត្រង់កថាខណ្ឌទី ២១ ។

[15] **E53/2/1**, អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើងថា "អនុស្សរណៈឆ្លើយតបទៅនឹងសំណើដែលបានដាក់ដោយមេធាវីការពារ (E53/2) អៀង សារី", ថ្ងៃទី១៥ មីនា ២០១១ ។ **E65/1**, អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើងថា "អនុស្សរណៈស្តីពីសេចក្តីសម្រេចលើសំណើរបស់ អៀង សារី ស្នើសុំដាក់សំណើសុំឱ្យមាន "ការបញ្ជាក់ថា គាត់នឹងត្រូវបានអនុញ្ញាតឱ្យបង្ហាញនូវទទ្បីករណ៍ផ្ទាល់មាត់ នៅពេលសវនាការបឋមស្តីអំពីអញ្ញត្រកម្មនីមួយៗរបស់គាត់"", ថ្ងៃទី១៦ មីនា ២០១១ ។ **E69/1**, សេចក្តីសម្រេចលើលើញត្តិរបស់ អៀង សារី ទាក់ទិននឹងការយកអង្គហេតុពីសំណុំរឿងលេខ ០០១ ដែលបានវិនិច្ឆ័យរួចហើយ និងអង្គហេតុនៃការដឹងឮជាទូទៅមកអនុវត្តក្នុងសំណុំរឿងលេខ ០០២, ថ្ងៃទី៤ មេសា ២០១១ ។ **E71/1**, សេចក្តីសម្រេចលើលើញត្តិរបស់ អៀង សារី សុំឱ្យមានសវនាការដេញដោលទៅលើការបំពេញកិច្ចស៊ើបសួរ, ថ្ងៃទី៨ មេសា ២០១១ ។

និងធានាដល់ការដឹកនាំរបស់ខ្លួនឲ្យបានឆាប់រហ័ស[16]។ គេសង្ឃឹមថា សវនាការទីមួយ នៅក្នុងករណីរឿងនេះអាចចាប់ផ្តើមបាននៅក្នុងពេលដ៏ខ្លីខាងមុខនេះ។ អាស្រ័យហេតុដូច្នេះ សហព្រះរាជអាជ្ញាស្នើដោយទទូច ឲ្យអង្គជំនុំជម្រះចេញសេចក្តីសម្រេច ឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន ដោយបង្គាប់ឲ្យជនជាប់ចោទធ្វើការថ្លែងបញ្ជាក់ក្នុងរយៈពេលចំនួនប្រាំពីរ(០៧)ថ្ងៃ គិតចាប់ពីថ្ងៃចេញដីកាបង្គាប់ ថាតើជនជាប់ចោទនឹងផ្តល់សក្ខីកម្ម ដែរ ឬទេ ឬមួយក៏គាត់អនុវត្តនូវសិទ្ធិរបស់គាត់ក្នុងការនៅស្ងៀមមិននិយាយ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី៣ ខែតុលា ឆ្នាំ២០១១ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក** Andrew CAYLEY<br>សហព្រះរាជអាជ្ញា | | [signature] |

[16] **E124,** ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩ស្ទួនពីរ នៃវិធានផ្ទៃក្នុង, ថ្ងៃទី២២ កញ្ញា ២០១១ ។ **E125,** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងមានចំណងជើងថា "ការបញ្ជាក់ជាបឋមអំពីខ្លឹមសារនៃសំណងដែលសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានបំណងទាមទារ ដោយអនុលោមតាមវិធាន ២៣ស្ទួនបួន(៣) នៃវិធានផ្ទៃក្នុង", ថ្ងៃទី២៣ កញ្ញា ២០១១ ។